CRITICAL ECOSYSTEM PARTNERSHIP FUND

BirdLife INTERNATIONAL in Indochina

# សេចក្តីសង្ខេបអំពីយុទ្ធសាស្រ្តវិនិយោគ  លក្ខណៈវិនិច្ឆ័យសមស្រប និងដំណើរការដាក់សំណើ

## ឥណ្ឌូ ~ ភូមា

## តំបន់ជីវៈចម្រុះដែលរងការគំរាមកំហែង

## (តំបន់ឥណ្ឌូចិន)

ខែ  មិថុនា  ឆ្នាំ  ២០០៩

# សង្ខេបអំពីយុទ្ធសាស្ត្រវិនិយោគ

## សេចក្តីផ្តើម

មូលនិធិភាពជាដៃគូសំរាប់ប្រពន្ធ័អេកូស៊ីស្ទែមដែលទទួលរងការគំរាមកំហែង(CEPF) ត្រូវបានបង្កើតឡើងដើម្បីការពារតំបន់ដែលសំបូរបែបដោយជីវៈចម្រុះ និងតំបន់រងការគំរាមកំហែងបំផុតនៅលើភពផែនដីដែលគេហៅថាជាតំបន់ជីវៈចម្រុះហតស្ពត (Biodiversity hotspots) ។ CEPF ត្រូវបានផ្តួចផ្តើមបង្កើតរួមគ្នាដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD), អង្គការអភិរក្សអន្តរជាតិ (CI), មូលនិធិបរិស្ថានពិភពលោក (GEF), រដ្ឋាភិបាលជប៉ុន, មូលនិធិម៉ាកាធ័រ (John D. and Catherine T. MacArthur) និងធនាគារពិភពលោក ។

គោលបំណងសំខាន់របស់ CEPF គឺដើម្បីផ្សារភ្ជាប់ទំនាក់ទំនងក្រុមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងសហគ្រាសឯកជនឱ្យចូលរួមក្នុងការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ជីវៈចម្រុះដែលរងការគំរាមកំហែង ។ CEPF ជំរុញឱ្យមានការប្រតិបត្តិការងារជាដៃគូរវាងស្ថាប័នផ្សេងៗគ្នា ការផ្តុំសមត្ថភាពគ្នាតែមួយ និងកាត់បន្ថយភាពជាន់គ្នានៃកិច្ចខិតខំប្រឹងប្រែងលើការងារអភិរក្ស ។ CEPF ផ្តោតចំណាប់អារម្មណ៍លើ តំបន់ជីវៈចម្រុះជាជាងព្រំប្រទល់រដ្ឋបាលរបស់ប្រទេសមួយៗ ហើយត្រួតពិនិត្យមើលការគំរាមកំហែងផ្សេងៗដែលកើតមានលើតំបន់អភិរក្សទាំងនោះផងដែរ ។ CEPF ផ្តោតគោលដៅលើការសហការឆ្លងព្រំដែននៅក្នុងតំបន់ណាដែលមានភាពសំខាន់ខ្លាំងសំរាប់ការអភិរក្សជីវៈចម្រុះដោយមិនគិតពីព្រំដែនប្រទេស ឬក៏នៅតំបន់ណាដែលការអភិរក្សក៏រិតតំបន់មានប្រសិទ្ធិភាពជាងការអភិរក្សក៏រិតជាតិ ។

ឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែម[1] បានឆ្លុះបញ្ចាំងទិដ្ឋភាពជាទូទៅនៃតំបន់ឥណ្ឌូចិនទាក់ទិននិងសារៈសំខាន់នៃការអភិរក្សជីវៈចម្រុះ ការគំរាមកំហែងទាំងឡាយ និងបុព្វហេតុនៃការបាត់បង់ជីវៈចម្រុះក្នុងតំបន់នេះ បរិបទសេដ្ឋកិច្ចសង្គម និងការវិនិយោគលើការអភិរក្សនាពេលបច្ចុប្បន្ន ។ វាបង្ហាញនូវលទ្ធផលដែលបានមកពីការអភិរក្សភាពខ្វះខាតនៃថវិកា និងឱកាសសំរាប់ការវិនិយោគ ហេតុដូច្នេះហើយនេះជាតួនាទីរបស់ CEPF ដែលត្រូវបំពេញនូវចំនុចខ្វះខាតទាំងនេះ ។

ឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែមក្នុងតំបន់ឥណ្ឌូចិន ត្រូវបានរៀបចំឡើងដោយការប្រជុំពិភាក្សាពិគ្រោះយោបល់ និងការសិក្សាស្រាវជ្រាវ ដែលសំរបសំរួលដោយអង្គការជីវិតសត្វស្លាបអន្តរជាតិក្នុងកិច្ចសហប្រតិបត្តិការជាមួយនិងសមាគមន៍អភិរក្សសត្វស្លាបរបស់ប្រទេសថៃ (BCST), កសិដ្ឋានកាដ្ឋូរិ និងសួនរុក្ខជាតិ (KFBG) និងអង្គការ WWF ប្រចាំនៅកម្ពុជា ដោយទទួលបានជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសំរាប់អនុវត្តវិទ្យាសាស្ត្រជីវសាស្ត្រចំរុះ (CABS) នៃអង្គការអភិរក្សអន្តរជាតិ ។ អ្នកពាក់ពន្ធ័ជាង១៧០នាក់មកពីស្ថាប័នសង្គមស៊ីវិលរដ្ឋាភិបាល និងម្ចាស់ជំនួយត្រូវបានអញ្ជើញចូលរួមប្រជុំពិភាក្សាពិគ្រោះយោបល់ក្នុងអំឡុងពេលរៀបចំឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែមនេះ ។

តំបន់ជីវៈចម្រុះហតស្ពតឥណ្ឌូ-ភូមាត្រូវបានចាត់ថ្នាក់ក្នុងចំណោមតំបន់ជីវៈចម្រុះរងការគំរាមកំហែងទាំង

[1] http://cepf.net/Documents/final.indoburma_indochina.ep.pdf

៨ ដែលបាត់បង់រុក្ខជាតិ និងសត្វមានឆ្អឹងកងជាច្រើន ដោយសារមូលហេតុមកពីការបំផ្លិចបំផ្លាញព្រៃឈើដែលនៅតែកើតមានមកទល់នឹងពេលបច្ចុប្បន្ននេះទៀត ។ ដោយសារតំបន់ជីវៈចម្រុះរងការគំរាមកំហែង(ហតស្ពត)ឥណ្ឌូ-ភូមាមានវិសាលភាពធំធេងពេក វាត្រូវបានបែងចែកជាពីរតំបន់តូចៗទៀតគឺ ឥណ្ឌូចិន និងភ្នំហេមពានភាគខាងកើត (Eastern Himalayas) ដែលតំបន់និមួយៗនឹងទទួលបាននូវមូលនិធិដាច់ដោយឡែកពីគ្នាពី CEPF ។ ក្រោយពីការរៀបចំផែនការរបស់ CEPF ក្នុងតំបន់ជីវៈចម្រុះរងការគំរាមកំហែងនេះ អង្គការអភិរក្សអន្តរជាតិក៏បានចេញផ្សាយនូវរបាយការណ៍វាយតម្លៃតំបន់ជីវៈចម្រុះរងការគំរាមកំហែងសាជាថ្មីម្តងទៀត ដោយជាផ្លូវការបែងចែកតំបន់នេះជាពីរដាច់ដោយឡែកពីគ្នា និងមានការផ្លាស់ប្តូរព្រំប្រទល់នៃតំបន់និមួយៗផងដែរ ។ ទោះបីជាបែបនេះក៏ដោយ CEPF ត្រូវជាប់កាតព្វកិច្ចក្នុងការប្រកាន់យកនូវព្រំប្រទល់នៃតំបន់ជីវៈចម្រុះដែលបានកំណត់ពីមុនមក ។ ចំពោះប្រទេសភូមាក្នុងដំណាក់កាលនេះមិនអាចបំពេញលក្ខខណ្ឌសមស្របដើម្បីដាក់សំណើសុំថវិកាពី CEPF បាន ឡើយ ។

តំបន់ឥណ្ឌូចិនបានបង្ហាញនូវភាពខុសប្លែកគ្នានៃភូមិសាស្ត្រដែលគួរអោយចាប់អារម្មណ៍យ៉ាងខ្លាំង ។ វាលាតសន្ធឹងពីរយៈកំពស់ជាង៣៥០០ម៉ែត្រពីកំពូលភ្នំនៃខេត្តយូណានប្រទេសចិនចុះទៅឆ្នេរសមុទ្រអាន់ដាម៉ាន់ ឈូងសមុទ្រថៃ និងសមុទ្រចិនភាគខាងត្បូង ។ ដោយសារមានភាពខុសប្លែកគ្នានៃសណ្ឋានដី និងតំបន់អាកាសធាតុយ៉ាងច្រើននេះហើយ ជាហេតុនាំឱ្យតំបន់ឥណ្ឌូចិនផ្តល់នូវទីជំរកក៏ដូចជាជីវៈចម្រុះដ៏ច្រើនសំបូរបែប ។

## លទ្ធផលនៃការអភិរក្ស

ឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែម CEPF សំរាប់តំបន់ឥណ្ឌូ-ភូមា បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែង និងការផ្តោតសំខាន់លើការប្រើប្រាស់លទ្ធផលនៃការអភិរក្ស (គោលដៅនៃភាពជោគជ័យរបស់ការវិនិយោគដែលអាចវាស់វែងបាន) ជាវិទ្យាសាស្ត្រជួយគាំទ្រដល់ការកំណត់នូវយុទ្ធសាស្ត្រវិនិយោគរបស់ CEPF ។ លទ្ធផលនេះបានជួយជំរុញឱ្យ CEPF ផ្តោតគោលដៅធនធានមានកំរិតរបស់តំបន់ទៅលើប្រភេទ ទីតាំង និងទេសភាពដែលជាការព្រួយបារម្ភរបស់ពិភពលោក ។ លទ្ធផលដែលអាចវាស់វែងបានទាំងនេះនឹងជួយឱ្យ CEPF អាចប្រមើលមើលឃើញពីភាពជោគជ័យនៃការវិនិយោគរបស់ខ្លួន ។

លទ្ធផលស្តែងចេញជាប្រភេទ ទីតាំង និងច្រករបៀងសំរាប់តំបន់ឥណ្ឌូចិន ត្រូវបានកំណត់ក្នុងពេលរៀបចំឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែមCEPFសំរាប់តំបន់ជីវៈចម្រុះរងការគំរាមកំហែងឥណ្ឌូ-ភូមា ហើយក្រោយមកត្រូវបានចាត់អាទិភាពជាផ្នែកមួយនៃការរៀបចំតួនាទី និងយុទ្ធសាស្ត្រវិនិយោគរបស់ CEPF ។

លទ្ធផលស្តែងចេញជាប្រភេទសត្វក្នុងតំបន់ឥណ្ឌូចិនរួមបញ្ចូលនូវរាល់ពូជសត្វទាំងឡាយណាដែលរងការគំរាមកំហែងក្នុងពិភពលោក (មានដូចជា ប្រភេទជិតផុតពូជបំផុត ប្រភេទជិតផុតពូជ និង ប្រភេទងាយរងគ្រោះ) ដោយផ្អែកតាម *បញ្ជីក្រហមនៃប្រភេទសត្វដែលទទួលការគំរាមកំហែងរបស់ IUCN ឆ្នាំ២០០២* ។ សំរាប់ឥណ្ឌូចិន តាមលទ្ធផលសិក្សាស្រាវជ្រាវបានបង្ហាញថាមានប្រភេទសត្វសរុបចំនួន **<u>៤៩២ប្រភេទ</u>** ។ ក្នុង៤៩២ប្រភេទនេះមាន**ថនិកសត្វ<u>៦០</u>ប្រភេទ សត្វស្លាប<u>៧៣</u>ប្រភេទ ឧរង្គសត្វ<u>៣៣</u>ប្រភេទ សត្វដែលអាចរស់នៅលើ**

**គោកផងក្នុងទឹកផង៤៦ប្រភេទ ត្រី៣២ប្រភេទ** និង**រុក្ខជាតិមាន២៤៨ប្រភេទ** ត្រូវបានជ្រើសរើសជាអាទិភាពសំរាប់ការទទួលបានថវិកាគាំទ្រពី CEPF ។ មកទល់និងពេលបច្ចុប្បន្ននេះ ការគំរាមកំហែងក្នុងកំរិតពិភពលោកលើប្រភេទសត្វគ្មានឆ្អឹងកងមិនទាន់ត្រូវបានគេធ្វើការសិក្សាវាយតម្លៃនៅឡើយទេក្នុងតំបន់ឥណ្ឌូចិន តែទោះជាយ៉ាងនេះក៏ដោយវាមិនមែនមានន័យថាក្រុមសត្វប្រភេទនេះគ្មានតំលៃក្នុងការអភិរក្សនោះទេ ។

ចំណែកឯទីតាំងវិញ លទ្ធផលបានបង្ហាញដោយកំណត់យកទីតាំងណាដែលមានប្រភេទសត្វកំពុងរងការគំរាមកំហែងកំរិតពិភពលោកយ៉ាងហោចណាស់មួយប្រភេទ ។ បញ្ជីដំបូងសំរាប់ប្រភេទសត្វ ទីតាំង និងច្រករបៀងជាអាទិភាពសំរាប់ការទទួលបានថវិកាគាំទ្រពី CEPF នៅក្នុងតំបន់ឥណ្ឌូចិនត្រូវបានស្នើឡើងក្នុងពេលប្រជុំតុមូលនៃអ្នកជំនាញកាលពីខែកក្កដា និងសីហា ឆ្នាំ២០០៣។ លទ្ធផលសិក្សាបង្ហាញពីទីតាំងអភិរក្សចំនួន**៣៦២** ក្នុងតំបន់ឥណ្ឌូចិនត្រូវបានស្នើឡើងសំរាប់ទទួលបានថវិកាវិនិយោគពីCEPFក្នុងអង្គប្រជុំតុមូលនៃអ្នកជំនាញ ជាលទ្ធផលអង្គប្រជុំបានសំរេចយកទីតាំងអាទិភាពចំនួន**៣០** ដែលអាចទទួលបានថវិកាវិនិយោគពីCEPF ។ ទីតាំងត្រូវបានចាត់ជាអាទិភាពដោយផ្អែកលើលក្ខណៈនៃទីកន្លែងដែលមិនអាចជំនួសបាន និងមានភាពងាយរងគ្រោះ ។ ទីតាំងភាគច្រើនមានប្រភេទសត្វដែលទទួលរងការគំរាមកំហែងកំរិតពិភពលោក ។ ជាពិសេសដូចជានៅ **ឆែប** ក្នុងប្រទេសកម្ពុជា, **ណាកៃ-ណាម ធឿន** និង **សេពៀន** នៅប្រទេសឡាវ, **ហ៊ាំងលានសាន** និង **ស៊ីហ៊ាំងបានណា** នៅចិនភាគខាងត្បូង, **ហាឡា-បាឡា ហ៊ួយខាឃាង** និង **ខៅបានថាដ** នៅប្រទេសថៃ និង **កែបាងង៉ក់លីញ ផង់ញ៉ា** និង **ភូម៉ាត** នៅប្រទេសវៀតណាម ដែលតំបន់នីមួយៗមានយ៉ាងហោចណាស់៣០ប្រភេទនៃពពួកសត្វដែលទទួលរងការគំរាមកំហែងកំរិតពិភពលោក ។

លទ្ធផលសិក្សាបង្ហាញពីច្រករបៀងសំរាប់អភិរក្សត្រូវបានកំណត់ដោយផ្អែកទៅលើតំរូវការបែបអេកូឡូស៊ីនៃតំបន់ទេសភាពដែលប្រភេទសត្វរស់នៅ ក៏ដូចជាដំណើរការអេកូឡូស៊ីសំខាន់ៗដទៃទៀតដូចជា ការបំលាស់ទីការសាយភាយ និងទំនាក់ទំនងអេកូឡូស៊ីផ្សេងៗទៀតដូចជាចលនាទឹកហូរជាដើម ។ ប្រភេទសត្វដែលរស់នៅក្នុងតំបន់ទេសភាពត្រូវការតំបន់ធំទូលាយដែរដើម្បីអាចរស់បាន ។ ច្រករបៀងដែលត្រូវអភិរក្សសរុបចំនួន**៩៣**កន្លែងត្រូវបានកំណត់នៅក្នុងតំបន់ឥណ្ឌូចិន សមមាត្រទៅនិង ៣៦% នៃផ្ទៃដីសរុបរបស់ឥណ្ឌូចិន រួមមានតំបន់ទំនាប **កែតូ** និង **ខៃណែត** និងច្រករបៀង**មូតូ ស៊ីម៉ីឡាន -ហ៊ី ហ៊ី-អានដាម៉ាន** ។

ការជ្រើសរើសទីតាំង និងច្រករបៀងជាអាទិភាពបានជួយជំរុញការវិនិយោគរបស់CEPF ក្នុងសកម្មភាពអភិរក្សកំរិតតំបន់ទេសភាព និងផ្អែកលើទីតាំង ឱ្យផ្តោតទៅលើទីតាំងភូមិសាស្ត្រ (ជាពិសេសគឺទីតាំង) ដែលមានអាទិភាពខ្ពស់បំផុត ខណៈដែលការជ្រើសរើសប្រភេទសត្វជាអាទិភាពជួយជំរុញការវិនិយោគរបស់CEPFក្នុងសកម្មភាពអភិរក្សប្រភេទសត្វ ឱ្យផ្តោតដោយផ្ទាល់លើប្រភេទសត្វរងការគំរាមកំហែងក្នុងពិភពលោក ជាមួយនិងតំរូវការអភិរក្សដែលមិនអាចឆ្លើយតបបានគ្រប់គ្រាន់នៃការអភិរក្សផ្អែកលើទីតាំង និងតំបន់ទេសភាពតែឯកឯងបាន ។

## ការពិចារណាសំខាន់ៗផ្សេងទៀត

ដំណើរការរៀបចំចងក្រងឯកសារប្រព័ន្ធអេកូស៊ីស្ទែមនេះក៏បានរួមបញ្ចូលនូវការវិភាគពីការគំរាមកំហែងលក្ខណៈសេដ្ឋកិច្ចសង្គម និងបច្ចុប្បន្នភាពនៃការវិនិយោគ ដើម្បីជួយរៀបចំជាយុទ្ធសាស្ត្រវិនិយោគដ៏មានប្រសិទ្ធិភាពបំផុត ។ ការគំរាមកំហែងចំបងៗដល់ជីវៈចម្រុះនៅឥណ្ឌូចិន រួមមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកំណើនប្រជាជន ។ ការគំរាមកំហែងសំខាន់ៗពីរដែលពពួករុក្ខជាតិ និងសត្វក្នុងតំបន់កំពុងជួបប្រទះនោះគឺការបាត់បង់ទីជំរក និងការធ្វើអាជីវកម្មហួសកំរិត ។ កត្តាមួយ ឬទាំងពីរនេះ គឺជាការគំរាមកំហែងដ៏ចំបងដល់ពពួកសត្វដែលរងការគំរាមកំហែងកំរិតពិភពលោកស្ទើរតែទាំងអស់ដែលមានវត្តមាននៅក្នុងតំបន់នេះ ។

តិចជាង៥%នៃតំបន់ឥណ្ឌូ-ភូមាត្រូវបានគ្របដណ្តប់ដោយព្រៃឈើនៅក្នុងលក្ខខ័ណ្ឌដែលមិនទាន់មានការរុករាន ខណៈដែលព្រៃដែលមានការបំផ្លាញតិចតួចនៅមានពី ១០% ទៅ ២៥% ។ នៅក្នុងកំរិតពិភពលោកតំបន់ជីវៈចម្រុះហតស្ពតឥណ្ឌូ-ភូមា គឺជាតំបន់មួយនៃតំបន់ដែលទទួលការគំរាមកំហែងច្រើនជាងគេ : វាមានចំណាត់ថ្នាក់ស្ថិតនៅក្នុងតំបន់រងការគំរាមកំហែងទាំង៨ ដែលបាត់បង់រុក្ខជាតិ និងសត្វមានឆ្អឹងកងជាច្រើន មូលហេតុដោយសារបាត់បង់ព្រៃឈើ ហើយនៅតែកើតមានជាបន្តមកទល់និងពេលបច្ចុប្បន្ននេះទៀត ។

មូលនិធិអន្តរជាតិសំរាប់ការអភិរក្សជីវៈចម្រុះនៅឥណ្ឌូចិនភាគច្រើនបានមកពី ឬតាមរយៈភ្នាក់ងារអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី។ អ្នកផ្តល់ជំនួយទ្វេភាគី ធ្វើការវិនិយោគជាសំខាន់ទៅលើការអភិរក្សនៅក្នុងតំបន់រួមមាន ជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសដាណឺម៉ាក (Danida), រដ្ឋាភិបាលជប៉ុន, រដ្ឋាភិបាលប្រទេសហូឡង់ និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ អ្នកផ្តល់ជំនួយពហុភាគីរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សហគមន៍អ៊ឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និងធនាគារពិភពលោក។ បន្ថែមពីលើនេះទៅទៀត នៅមានគំរោងដែលផ្តល់មូលនិធិដោយ GEF សំខាន់ៗមួយចំនួនទៀតនៅក្នុងតំបន់ដែលបានអនុវត្តតាមរយៈ UNDP ឬ ធនាគារពិភពលោក ។

សន្ទស្សន៍នៃការបែងចែកសំរាប់គំរោងជីវៈចម្រុះដែលបានដាក់ចេញក្នុងដំណាក់កាលទី៤នាពេលថ្មីៗនេះរបស់មូលនិធិបរិស្ថានពិភពលោក (GEF) សំរាប់៤ប្រទេសនៅក្នុងតំបន់ហតស្ពតឥណ្ឌូចិនមាន : ប្រទេសចិន ៤៤,៣លានដុល្លារ ប្រទេសឡាវ៥,២លានដុល្លារ ប្រទេសថៃ៩,២លានដុល្លារ និងប្រទេសវៀតណាម ១០,២លានដុល្លារ ។ ប្រទេសកម្ពុជាមិនមានតួលេខច្បាស់លាស់ទេ ប៉ុន្តែវាស្ថិតនៅក្នុងចំណោមក្រុមប្រទេសតូចៗទាំង៩៣ប្រទេសដែលទទួលបានថវិកាសរុបចំនួន ១៤៦,៨លានដុល្លារ ។ ប្រទេសនិមួយៗអាចទទួលបានថវិការហូតដល់ ៣,៥លានដុល្លារពី GEF ដំណាក់កាលទី៤នេះ ប៉ុន្តែជំនួយជាមធ្យមគឺ ប្រហាក់ប្រហែលនិង១,៥លានដុល្លារប៉ុណ្ណោះ ។ ថវិកាច្បាស់លាស់មិនត្រូវបានគេធានាចំពោះប្រទេសដែលអាចទទួលមូលនិធិរបស់GEFទេ ប៉ុន្តែតួលេខជាក់ស្តែងទំនងជាប្រហាក់ប្រហែលនឹងសន្ទស្សន៍នៃការបែងចែកដែលបានផ្តល់ទៅឱ្យរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ ។

## ចំណាប់អារម្មណ៍របស់ CEPF និង យុទ្ធសាស្ត្រវិនិយោគ

ពពួកសត្វដែលរងការគំរាមកំហែងក្នុងពិភពលោក គឺជាមូលដ្ឋានគ្រឹះសំរាប់ការកំណត់លទ្ធផលនៃការអភិរក្សសំរាប់តំបន់ឥណ្ឌូចិន ហើយបន្ទាប់មកជាការកំណត់លើអាទិភាពវិនិយោគរបស់ CEPF ។

ការយកចិត្តទុកដាក់ជាចំបងសំរាប់ការវិនិយោគរបស់ CEPF ត្រូវបានបង្កើតឡើងផ្អែកលើការវិភាគនៃលទ្ធផលអភិរក្ស ការគំរាមកំហែងចំបងៗ សេដ្ឋកិច្ចសង្គមជាក់ស្តែង សមត្ថភាពស្ថាប័នរបស់សង្គមស៊ីវិលនៅក្នុងតំបន់ និងការប៉ាន់ប្រមាណនៃការវិនិយោគបច្ចុប្បន្ននៅក្នុងតំបន់ ។

ការផ្លាស់ប្តូរស្ថានភាពនយោបាយនៅក្នុងប្រទេសជាច្រើនមានន័យថា កើនឡើងនូវជំនួយអន្តរជាតិរួមទាំងការវិនិយោគលើការអភិរក្សផងដែរ ដែលបានហូរចូលទៅក្នុងប្រទេសជាច្រើននៅក្នុងតំបន់ចាប់តាំងពីទសវត្សឆ្នាំ៩០មកម្ល៉េះ ។ ក្នុងកំឡុងពេលនោះ រដ្ឋាភិបាលប្រទេសនិមួយៗក៏បានធ្វើការវិនិយោគដ៏សំខាន់លើការងារអភិរក្សផងដែរ ជាពិសេសតាមរយៈការពង្រីកនូវបណ្តាញតំបន់ការពារថ្នាក់ជាតិ ។ សង្គមស៊ីវិល គឺជាស្ថាប័នដ៏ប្រសើរដើម្បីទប់ស្កាត់ទាំងការគំរាមកំហែងផ្សេងៗដល់ពូជសត្វ ទីតាំង និងប្រព័ន្ធអេកូស៊ីស្ទែម ក៏ដូចជារកឱ្យឃើញមូលហេតុដែលនៅពីក្រោយបញ្ហានោះផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិនិយោគនាពេលបច្ចុប្បន្នជាទូទៅមិនផ្តោតគោលដៅលើការអភិរក្សជាអាទិភាពចំបងបំផុត ឬអនុវត្តនូវវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពនោះទេ ។ ដូច្នេះឱកាសសំរាប់ CEPF ដើម្បីជួយគាំទ្រដល់ការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ គឺមិនមានព្រំដែនកំនត់ឡើយ ។

ការយកចិត្តទុកដាក់ជាចំបងរបស់ CEPF សំរាប់ការវិនិយោគនៅក្នុងតំបន់ឥណ្ឌូចិនត្រូវបានបង្កើតតាមរយៈដំណើរការចូលរួមដោយមានវត្តមានសង្គមស៊ីវិល ម្ចាស់ជំនួយ និងរដ្ឋាភិបាលនៅទូទាំងតំបន់ ។ ធនធានបន្ថែមតែនៅមានកំរិតរបស់CEPF អាចត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពបំផុតនៅក្នុងការគាំទ្រលើគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលដែលបំពេញបន្ថែម និងផ្តោតគោលដៅចំការវិនិយោគដែលមានស្រាប់ ។ យុទ្ធសាស្ត្រវិនិយោគសំរាប់តំបន់ឥណ្ឌូចិនរួមមាន ***១២អាទិភាពវិនិយោគ*** ឬ ***៤ទិសដៅយុទ្ធសាស្ត្រ*** (តារាង១) ដែលនេះជាលទ្ធផលបានពីដំណើរការប្រជុំពិគ្រោះយោបល់ដ៏ផុលផុសជាមួយនិងសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាល ។

**តារាង ១ ទិសដៅជាយុទ្ធសាស្ត្រ និង ការវិនិយោគជាអាទិភាពរបស់ CEPF នៅតំបន់ឥណ្ឌូចិន**

| ទិសដៅយុទ្ធសាស្ត្ររបស់ CEPF | ការវិនិយោគជាអាទិភាពរបស់ CEPF |
|---|---|
| **១. ការការពារជាអាទិភាពដល់ប្រភេទដែលទទួលរងការគំរាមកំហែងកំរិតពិភពលោកនៅឥណ្ឌូចិន ដោយកាត់បន្ថយការគំរាមកំហែងចំបងៗ** | ១.១ កំណត់ និង សង្គ្រោះដល់ពពួកសត្វសំខាន់ៗដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកចំនួន ៦៧ប្រភេទពីការធ្វើអាជីវកម្មហួសកំរិត និងជំនួញខុសច្បាប់ |
| | ១.២ អនុវត្តយុទ្ធនាការផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ ដើម្បីជួយពង្រឹងការអនុវត្តគោលនយោបាយដែលមានស្រាប់ស្តីពីអាជីវកម្មសត្វព្រៃ និងចូលរួមកាត់បន្ថយតំរូវការរបស់អ្នកប្រើប្រាស់លើពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកទាំង ៦៧ ប្រភេទ និងផលិតផលទាំងឡាយដែលផលិតចេញពីពួកវា ។ |
| | ១.៣ សិក្សាស្រាវជ្រាវពីស្ថានភាព និងរបាយនៃពពួករុក្ខជាតិដែលទទួលរងការគំរាមកំហែងក្នុងពិភពលោក ហើយលទ្ធផលដែលរកឃើញត្រូវបានយកទៅធ្វើផែនការ គ្រប់គ្រង និងបង្កើនការយល់ដឹង ។ |
| | ១.៤ សិក្សាវាយតម្លៃពីស្ថានភាពគំរាមកំហែងកំរិតពិភពលោកនៃចំណាត់ថ្នាក់ប្រភេទទឹកសាបដែលបានជ្រើសរើស និងបញ្ចូលលទ្ធផលដែលរកឃើញទៅក្នុងដំណើរការរៀបចំផែនការសំរាប់ការអភិរក្សនៃជីវៈចម្រុះតំបន់ដីសើម និងទៅក្នុងផែនការអភិវឌ្ឍន៏ក្នុងទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា ។ |
| | ១.៥ ធ្វើការស្រាវជ្រាវលើប្រភេទសត្វទាំង ១២ប្រភេទ ( ថនិកសត្វ, សត្វស្លាប និងសត្វល្មូន) ដើម្បីធ្វើបច្ចុប្បន្នភាពទូវពតិមានស្តីពីស្ថានភាព និងរបាយរបស់ពួកវា ។ |
| | ១.៦ បោះពុម្ពឯកសារស្តីពីពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកជាភាសាជាតិ ។ |
| **២. បង្កើតជាវិធីសាស្ត្រថ្មីដែលដឹកនាំដោយសហគមន៏មូលដ្ឋានក្នុងការអភិរក្សដោយផ្អែកលើទីតាំងនៅតំបន់ជីវៈចម្រុះសំខាន់ៗទាំង២៨កន្លែង** | ២.១ បង្កើតវិធីសាស្ត្រគ្រប់គ្រងការអភិរក្សតាមរបៀបថ្មីមួយដោយមានការចូលរួមពីអ្នកពាក់ពន្ធ័ និងការផ្តួចផ្តើមការពារក្នុងតំបន់ជីវៈចម្រុះសំខាន់ៗទាំង២៨កន្លែង |
| | ២.២ បង្កើតនូវស្តង់ដារ និងកម្មវិធីជាលក្ខណៈតំបន់ដែលទប់ស្កាត់នូវរាល់ការធ្វើអាជីវកម្មហួសកំរិតលើជីវៈចម្រុះ និងអនុវត្តកម្មវិធីសាកល្បងនៅតំបន់ដែលបានជ្រើសរើស ។ |

| | |
|---|---|
| **៣. ធ្វើឱ្យអ្នកពាក់ព័ន្ធ សំខាន់ៗចូលរួមក្នុងការសំរបសំរួលការងារអភិរក្សជីវៈចម្រុះ និងគោលដៅអភិវឌ្ឍន៍ ដោយផ្តោតសំខាន់លើតំបន់ភ្នំខ្ពង់រាបភាគខាងជើង និងទន្លេមេគង្គ ព្រមទាំងដៃសំខាន់ៗរបស់វា** | ៣.១ គាំទ្រដល់ការខំប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការវិភាគនូវកម្មវិធី ផែនការ និងគោលនយោបាយអភិវឌ្ឍន៍នានា ដោយវាយតំលៃពីផលប៉ះពាល់លើជីវៈចម្រុះ និងប្រពន្ធ័អេកូស៊ីស្ទែម ព្រមទាំងស្នើឡើងនូវជំរើសផែនការអភិវឌ្ឍន៍ថ្មី និងវិធានការសមស្របផ្សេងៗទៀតដើម្បីកាត់បន្ថយផលប៉ះពាល់នោះ ។ |
| | ៣.២ គាំទ្រដល់ការផ្តួចផ្តើមដែលបង្កើនការគាំទ្រដល់ការអភិរក្សជីវៈចម្រុះ ចេញពីគំរោង និងកម្មវិធីអភិវឌ្ឍន៍ |
| | ៣.៣ បង្កើនការយល់ដឹងដល់អ្នកធ្វើការសំរេចចិត្ត អ្នកសារពត៌មាន និងអ្នកច្បាប់ |
| **៤. ផ្តល់ភាពដឹកនាំជាយុទ្ធសាស្ត្រ និងការសំរបសំរួលការវិនិយោគរបស់ CEPF ប្រកបដោយប្រសិទ្ធិភាព តាមរយៈក្រុមការងារប្រចាំតំបន់** | ៤.១ កសាងក្រុមការងារសង្គមស៊ីវិលដើម្បីធ្វើការទំនាក់ទំនងឆ្លងស្ថាប័ន និងនយោបាយ ឆ្ពោះទៅរកការសំរេចឱ្យបាននូវទិសដៅរួមនៃការអភិរក្ស ដូចដែលបានរៀបរាប់នៅក្នុងឯកសារប្រពន្ធ័អេកូស៊ីស្ទែមនេះ ។ |

**<u>ទិសដៅជាយុទ្ធសាស្ត្រទី ១</u> : ការពារជាអាទិភាពដល់ពពួកសត្វដែលទទួលរងការគំរាមកំហែងកំរិតពិភពលោកនៅក្នុងតំបន់ឥណ្ឌូចិនដោយកាត់បន្ថយការគំរាមកំហែងធំៗ**

ឥណ្ឌូចិនគឺជាតំបន់មួយនៃតំបន់សំខាន់បំផុតនៅក្នុងពិភពលោកសំរាប់ការអភិរក្សពពួកសត្វដែលទទួលរងការគំរាមកំហែងកំរិតពិភពលោក ។ តំបន់នេះមានពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកចំនួន ៤៩២ ប្រភេទ ហើយប្រភេទសត្វជាច្រើនគេមិនឃើញមាននៅតំបន់ផ្សេងឡើយ ។ សំរាប់ពពួកដែលមានចំណាត់ថ្នាក់ជាក់លាក់ដូចជាពពួកថនិកសត្វថ្នាក់ខ្ពស់ តំបន់ឥណ្ឌូ-ភូមា (ភាគច្រើននៅតំបន់ឥណ្ឌូចិន) មានពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកច្រើនជាងតំបន់ជីវៈចម្រុះហតស្ពតផ្សេងៗទៀត ។ ឥណ្ឌូចិនក៏ត្រូវបានគេព្យាករណ៍ផងដែរថានៅមានប្រភេទដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកជាច្រើនបន្ថែមទៀតនៅក្នុងពពួកដែលការវាយតម្លៃការគំរាមកំហែងនៅកំរិតពិភពលោកមិនទាន់ត្រូវបានគេធ្វើនៅឡើយដូចជាពពួកសត្វដែលគ្មានឆ្អឹងកង ត្រី និងរុក្ខជាតិ ។

បើទោះបីជាតំបន់ឥណ្ឌូចិនមានសារៈប្រយោជន៍សំខាន់សំរាប់ការអភិរក្សប្រភេទដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកក៏ដោយ ក៏ការវិនិយោគលើការងារអភិរក្សក្នុងតំបន់នេះនៅមានកំរិតតិចតួចណាស់ក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ ហើយការអភិរក្សនោះទៀតសោតគឺផ្តោតលើប្រភេទ ។ នេះឆ្លុះបញ្ចាំងពីការរួមចំណែករបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និង NGO ដែលអភិរក្សជាគំរូលើប្រពន្ធ័អេកូស៊ីស្ទែមធម្មជាតិ ជាសំខាន់តាមរយៈការបង្កើតនូវតំបន់ការពារ ដែលវានឹងគ្រប់គ្រាន់ដើម្បីរក្សានូវចំនួនពពួកសត្វអោយរស់នៅបាន ។

**<u>ទិសដៅជាយុទ្ធសាស្ត្រទី២ :</u> បង្កើតជាវិធីសាស្ត្រថ្មីដែលដឹក នាំដោយសហគមន៍មូលដ្ឋានក្នុងការអភិរក្សដោយផ្អែកលើទីតាំងនៅក្នុងតំបន់ជីវៈចម្រុះសំខាន់ៗទាំង២៨កន្លែង**

មានការវិនិយោគរបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅក្នុងការអភិរក្សដោយផ្អែកលើទីតាំងនៅក្នុងប្រទេសនីមួយៗក្នុងតំបន់ ។ ទោះបីជាយ៉ាងនេះក៏ដោយ ការវិនិយោគជាច្រើនមកទល់និងសព្វថ្ងៃនេះត្រូវបានគេប្រមូលផ្តុំតែទៅលើតំបន់ការពារ និងផ្តោតសំខាន់ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់សម្ភារៈបរិក្ខារប្រើប្រាស់ និងសកម្មភាពបង្កើនប្រាក់ចំណូលសំរាប់សហគមន៍មូលដ្ឋាន ។ ចំណុចយកចិត្តទុកដាក់សំខាន់សំរាប់ការផ្តល់មូលនិធិ CEPF គឺគាំទ្រសង្គមស៊ីវិលដើម្បីពង្រឹងសមត្ថភាពមន្ត្រីប្រតិបត្តិ ក្នុងការត្រួតពិនិត្យនូវការធ្វើអាជីវកម្មហួសកំរិតក្នុងតំបន់ការពារ ។ អង្គការសង្គមស៊ីវិលជាច្រើនត្រូវបានបង្កើតដើម្បីបំពេញតួនាទីនេះ ពីព្រោះដោយសារជំនាញ និងបទពិសោធន៍របស់គេនៅក្នុងផ្នែកនេះ ហើយបានបង្ហាញពីភាពជោគជ័យជាច្រើននៅក្នុងតំបន់ ។ វិធីសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុតនោះគឺ រៀបចំជាស្តង់ដារតំបន់ និងកម្មវិធីបណ្តុះបណ្តាល ដោយផ្អែកលើទំលាប់អនុវត្តប្រសើរបំផុតដែលបានបង្កើតហើយ ។ ជាងនេះទៅទៀត សង្គមស៊ីវិលត្រូវបានកំណត់ដើម្បីឱ្យអ្នកពាក់ព័ន្ធនៅមូលដ្ឋានទាំងអស់ចូលរួមក្នុងការអភិរក្សលើទីតាំង ។ ជាញឹកញយ នេះជាជំរើសដ៏មានប្រសិទ្ធិភាពបំផុតចំពោះការវិនិយោគនៅក្នុងការគ្រប់គ្រងតំបន់ការពារ និងជាឱកាសដ៏ប្រសើរក្នុងការផ្តល់អំណាចទៅឱ្យសហគមន៍មូលដ្ឋានដើម្បីគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព ។

**<u>ទិសដៅជាយុទ្ធសាស្ត្រទី៣ :</u> ធ្វើឱ្យអ្នកពាក់ព័ន្ធសំខាន់ៗចូលរួមក្នុងការសំរបសំរួលការងារអភិរក្សជីវៈចម្រុះ និងគោលដៅអភិវឌ្ឍន៍ ដោយផ្តោតសំខាន់លើតំបន់ភ្នំខ្ពង់រាបភាគខាងជើង និងទន្លេមេគង្គ ព្រមទាំងដៃសំខាន់ៗរបស់វា**

អន្តរាគមន៍លើការអភិរក្សនៅក្នុងតំបន់នាពេលបច្ចុប្បន្ននេះមានទំនោរផ្តោតទៅលើការទប់ស្កាត់ជាបន្ទាន់លើការគំរាមកំហែងដល់ជីវៈចម្រុះជាជាងរកឱ្យឃើញនូវមូលហេតុដែលនៅពីខាងក្រោយវា ។ ថ្វីត្បិតតែវិធីសាស្ត្រនេះបានទទួលលទ្ធផលជោគជ័យមួយចំនួននៅតំបន់ជាក់លាក់ ឬសំរាប់ពពួកសត្វជាក់លាក់ណាមួយពិតមែន ក៏ប៉ុន្តែជារួមវានៅតែមានការបំផ្លិចបំផ្លាញ និងការបាត់ជំរកធម្មជាតិ ព្រមទាំងថយចុះចំនួនពពួកសត្វដែលរងការគំរាមកំហែងក្នុងពិភពលោកនោះផងដែរ ។ មូលហេតុដែលនៅពីក្រោយបញ្ហានោះគឺ ដោយសារការអោយអាទិភាពទាបលើការអភិរក្សជីវៈចម្រុះរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយភាគច្រើន ការអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចដែលមិនស្របគ្នាទៅនិងការអភិរក្សជីវៈចម្រុះ និងកង្វះខាតការការពារបរិស្ថានក្នុងគំរោងអភិវឌ្ឍនានាផ្តល់មូលនិធិដោយរដ្ឋាភិបាល និងម្ចាស់ជំនួយ ។ ជាជាងសម្លឹងមើលមូលហេតុពីខាងលើថាជាឧបសគ្គដែលមិនអាចដោះស្រាយបាននោះ យើងគួរគិតថានេះជាឱកាសសំរាប់សង្គមស៊ីវិលដើម្បី "ជ្រៀតចូល" ក្នុងការងារអភិរក្សជីវៈចម្រុះធ្វើយ៉ាងណាដើម្បីបន្ថយការគំរាមកំហែងមុនពេលដែលវាកើតឡើង និងស្វះស្វែងរកធនធានឱ្យបានគ្រប់គ្រាន់រួមទាំងការគាំទ្រផ្នែកនយោបាយសំរាប់ឈានទៅរកភាពជោគជ័យនៃការងារអភិរក្ស ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៤ : ផ្តល់ភាពដឹកនាំជាយុទ្ធសាស្ត្រ និងការសំរបសំរួលការវិនិយោគរបស់CEPF ប្រកបដោយប្រសិទ្ធិភាព តាមរយៈក្រុមការងារប្រចាំតំបន់**

ការវាយតំលៃឯករាជ្យមួយនៃកម្មវិធីរបស់ CEPF នៅក្នុងពិភពលោក បានរកឃើញថាក្រុមការងាររបស់CEPFប្រចាំតំបន់ផ្តល់នូវប្រសិទ្ធិភាពជាពិសេសក្នុងការគាំទ្រដល់នាយកមូលនិធិ CEPF ក្នុងការផ្សារភ្ជាប់នូវសមាសធាតុសំខាន់ៗដែលមានលក្ខណៈធំទូលាយតាមលំដាប់នៃការវិនិយោគដូចជាគំរោងធំមានភាពយូរអង្វែង សកម្មភាពតូចៗរបស់ប្រជាជនថ្នាក់មូលដ្ឋាន ការបង្កើតនូវគោលនយោបាយថ្មី ការសហការជាមួយរដ្ឋាភិបាល និងនិរន្តភាពហិរញ្ញវត្ថុជាដើម ។ ដោយបានអនុសាសន៍ពីអ្នកវាយតំលៃ ការទទួលខុសត្រូវនៃក្រុមនេះ (ដែលពីមុនហៅថាផ្នែកសំរបសំរួល) ឥឡូវត្រូវបានធ្វើអោយមានលក្ខណៈស្តង់ដារក្នុងការបំពេញមុខងារដ៏សំខាន់ខ្លួន ។

នៅក្នុងតំបន់ឥណ្ឌូ-ភូមា CEPFនឹងគាំទ្រអង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំតំបន់ឥណ្ឌូចិនក្នុងការបំពេញតួនាទីជាក្រុមការងារប្រចាំតំបន់ ដែលនឹងបំលែងផែនការដែលមានចែងក្នុងឯកសារស្តីពីប្រព័ន្ធអេកូស៊ីស្ទែមឱ្យទៅជាសកម្មភាពផ្តល់ជំនួយជាក់ស្តែង ។ អង្គការជីវិតសត្វស្លាបអន្តរជាតិគ្រោងនិងឱ្យស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតចូលរួមត្រួតពិនិត្យការអនុវត្តការងារនេះ ដោយបង្កើតឱ្យមានជាគណកម្មការប្រឹក្សាប្រឹក្សាយោបល់ និងក្រុមត្រួតពិនិត្យផ្នែកបច្ចេកទេសប្រចាំប្រទេសនិមួយៗផងដែរ ។

**ពពួកសត្វអាទិភាព**

ប្រភេទសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកចំនួន **<u>៦៧ ប្រភេទ</u>** ត្រូវបានជ្រើសរើសជាប្រភេទសត្វអាទិភាព ដែលត្រូវជា២៧%នៃបញ្ជីទាំងមូលនៃពពួកសត្វដែលរងការគំរាមកំហែងក៏រិតពិភពលោកនៅក្នុងតំបន់ឥណ្ឌូចិន (តារាង ២) ។ ពពួកសត្វអាទិភាព រួមមានពពួក**ថនិកសត្វថ្នាក់ខ្ពស់៧ប្រភេទ** ដែលមានតែក្នុងតំបន់ឥណ្ឌូចិននេះ **ពពួកទំសាសត្វ៨ ប្រភេទ** និង **ពពួកអណ្តើក ២០ប្រភេទ** ការគំរាមកំហែងខ្ពស់ទៅលើក្រុមទាំងនេះឆ្លុះបញ្ចាំងតាមរយៈការធ្វើអាជីកម្មហួសកំរិត និងភាគច្រើនពីតំរូវការជំនួញសត្វព្រៃ ។ ពពួកសត្វអាទិភាពក៏រួមបញ្ចូលនូវ**សត្វស្លាបទឹកប្រភេទធំ និងមធ្យម ៧ប្រភេទ** ដែលបង្កាត់ពូជជាទ្រង់ទ្រាយតូច ឬបង្កាត់ពូជជាទ្រង់ទ្រាយធំ ហើយដែលមានវត្តមានរាយប៉ាយពាសពេញក្នុងអំឡុងរដូវមិនបង្កាត់ពូជ ពពួកសត្វទាំងនេះតំរូវការសកម្មភាពអភិរក្សផ្តោតលើពូជសត្វតាមដំណាក់កាលដើម្បីដោះស្រាយការធ្វើអាជីកម្មហួសហេតុ ការរំខាន និងការបាត់បង់ជំរកសំខាន់ៗ ។ ជាងនេះទៅទៀត ពពួកសត្វជាអាទិភាព ១២ ប្រភេទទៀតត្រូវបានជ្រើសរើសពីព្រោះមានតំរូវការចាំបាច់សំរាប់ធ្វើបច្ចុប្បន្នភាពនូវពត៌មានអំពីស្ថានភាព និងរបាយរបស់ពួកវា មុនពេលដែលសកម្មភាពអភិរក្សអាចត្រូវបានគេធ្វើក្នុងមធ្យោបាយសមស្របបំផុត ។ ក្នុងចំណោមទាំង១២ប្រភេទនោះមាន ៩ប្រភេទ គឺជាពពួកសត្វដែលជិតផុតពូជ ។

បន្ថែមពីលើពពួកសត្វជាអាទិភាពដែលបានរៀបរាប់នៅក្នុងតារាងទី ៩ ពពួករុក្ខជាតិទទួលរងការគំរាមកំហែងក្នុងពិភពលោកទាំងអស់ **<u>២៤៨ ប្រភេទនៅក្នុងឥណ្ឌូចិន</u>** ក៏ត្រូវបានចាត់ទុកជាអាទិភាពសំរាប់ការវិនិយោគរបស់ CEPF ផងដែរ ។ សកម្មភាពអភិរក្សជាអាទិភាពសំរាប់ពពួករុក្ខជាតិដែលទទួលរងការគំរាមកំហែងក៏រិត

ពិភពលោកដែលមានច្រើនលើសលប់នៅក្នុងតំបន់នេះ គឺការសិក្សាស្រាវជ្រាវដើម្បីបង្ហាញពីស្ថានភាព និងរបាយរបស់ពួកវា ។

## ច្រករបៀងអាទិភាព និង ទីតាំងអាទិភាព

យុទ្ធសាស្ត្រវិនិយោគរបស់CEPF ផ្តោតគោលដៅលើ**ច្រករបៀងអាទិភាព ២** និង **ទីតាំងអាទិភាព ២៨** ដែលមានបង្ហាញក្នុង (រូបភាព ១ និង តារាង ១) ។ ច្រករបៀងអាទិភាពទាំងពីរនេះគ្របដណ្តប់លើផ្ទៃដីសរុប ៤១.៥៤៧គម$^{២}$ និងមានតំបន់ជីវៈចម្រុះសំខាន់២៨កន្លែងនៅក្នុងនេះ ស្មើនឹង៨%នៃបញ្ជីទាំងមូលសំរាប់ឥណ្ឌូចិន ។ តំបន់ជីវៈចម្រុះសំខាន់ៗទាំងអស់នេះត្រូវបានជ្រើសរើសជាទីតាំងអាទិភាព ។

រូបភាព ១ — ច្រករបៀងជាអាទិភាពសំរាប់ការវិនិយោគរបស់ CEPF នៅឥណ្ឌូចិន




ដោយបានសំរេចតាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់ពីអ្នកពាក់ពន្ធ័ ច្រករបៀងតាមទន្លេមេគង្គ និងដៃសំខាន់ៗមិនរាប់បញ្ចូលតំបន់ដីសន្ទទន្លេមេគង្គក្រោមចុះពីភ្នំពេញនោះទេ ។

## <u>ច្រករបៀងអាទិភាពទី ១-តំបន់ភ្នំខ្ពង់រាបភាគខាងជើង</u>

ច្រករបៀងតំបន់ខ្ពង់រាបភាគខាងជើងមានសារៈសំខាន់ជាពិសេសសំរាប់ការអភិរក្សពពួកថនិកសត្វថ្នាក់ខ្ពស់ ដោយសារវាមានចំនួនទាំងអស់របស់ពិភពលោកនៃពួកស្វាច្រមុះខ្លី *(Tonkin snub-nosed monkey)* ដែលជិតផុតពូជបំផុត និងចំនួនដ៏ច្រើនជាងគេលើពិភពលោករបស់សត្វទោចកំប៉ោយខ្មៅភាគខាងកើត (Eastern

black crested gibbon, *Nomascus concolor nasutus*) ដែលត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជាពូជសត្វដែលជិតផុតពូជបំផុត ។ ច្រករបៀងនេះក៏ជាកន្លែងដ៏សំខាន់ជាលក្ខណៈពិភពលោកសំរាប់ការអភិរក្សពពួករុក្ខជាតិ ដោយសារវាមានប្រភេទដុះដោយតំបន់ជាច្រើនដូចជាពពួកអរគីដេ ។ ច្រករបៀងនេះគាំទ្រពពួកស្រល់ដែលនៅផ្តុំគ្នាជាច្រើននៅក្នុងតំបន់ រួមទាំងប្រភេទដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកជាច្រើនដូចជា *Amentotaxus yunnanensis*, *Cephalotaxus mannii* និង *Cunninghamia konishii* ។ គួរកត់សំគាល់ថាភាគច្រើននៃច្រករបៀងមានពពួកដើមស្រល់ ២ប្រភេទ ដែលជាពូជមាននៅតែទីតាំងមួយគឺ : *Xanthocyparis vietnamensis* និង *Amentotaxus hatuyenensis*4 ។ ឆ្លងតាមរយៈប្រវត្តិនៃការប្រើប្រាស់ដីនៃអាជីវកម្មកាប់ឈើ និងការរានដីសំរាប់កសិកម្មពនេចរ ជំរកធម្មជាតិនៃច្រករបៀងខ្ពង់រាបភាគខាងជើង (ដែលជាតំបន់ថ្មកំបោរ ព្រៃស្រោងតំបន់ទំនាប និងព្រៃស្រោងតំបន់ភ្នំ) ត្រូវបានពុះជាបំណែកៗ ហើយប្លុកដែលនៅសល់ជាញឹកញាប់ត្រូវបានទទួលរងការគំរាមកំហែងដោយការធ្វើអាជីវកម្មហួសកំរិតនៃផលិតផលព្រៃឈើ ។ យ៉ាងណាក៏ដោយច្រករបៀងបង្ហាញនូវឱកាសដ៏ល្អក្នុងការជំរុញអោយមានការពាក់ព័ន្ធពីសង្គមស៊ីវិលនៅក្នុងការអភិរក្សជីវៈចម្រុះ ។ ចំនួនដែលសំខាន់ៗជាងគេបំផុតជាច្រើននៃពពួកដែល ទទួលរងការគំរាមកំហែង និងជិតផុតពូជកើតឡើងនៅក្រៅតំបន់ការពារផ្លូវការ ពោលគឺក្នុងទីតាំងដែលអាចអោយគេធ្វើការអភិរក្សតាមវិធីសាស្ត្រពឹងផ្អែកលើសហគមន៍ ។ ជាងនេះទៅទៀតតំបន់ជីវៈចម្រុះសំខាន់ៗជាច្រើន ត្រូវបានរងការគំរាមកំហែងដោយគំនិតផ្តួចផ្តើមអភិវឌ្ឍន៍មិនរលូន ហេតុនេះសង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការសំរបសំរួលរបៀបវារៈនៃការអភិរក្សនិងអភិវឌ្ឍន៍នៅច្រករបៀង ។

**តារាង ១ ច្រករបៀងអាទិភាព និង តំបន់អាទិភាពសំរាប់ការវិនិយោគ CEPF នៅឥណ្ឌូចិន**

| **ច្រករបៀងអាទិភាព** | **តំបន់អាទិភាព** | **ប្រទេស** | **ផ្ទៃដី (គម²)** |
|---|---|---|---|
| **ទន្លេមេគង្គ និងដៃសំខាន់ៗ** | តំបន់វាលភក់បាសិត, បឹងវាលសំណាប, ដៃទន្លេមេគង្គនៅក្បែរប៉ាកចម, មេគង្គពីខេត្តក្រចេះទៅដល់ឡាវ, មេគង្គពីភូស៊ាងថងទៅដល់ស៊ីផាន់ដុន, មេគង្គលើនៅវៀងច័ន្ទ, ទន្លេសេកុង, ទន្លេសេសាន, ស៊ីផាដុន, ផ្នែកខាងលើទន្លេមេគង្គឡាវ, ផ្នែកខាងលើសែខាម៉ាន | កម្ពុជា ឡាវ ចិន និង ថៃ | ១៧ ០៧០ |
| **តំបន់ខ្ពង់រាបខាងជើង** | បាបៃ, បានប៊ុង, បានធីស៊ាន់ឡាក, បិញអាន, ចាំជូ, ឌីឌីង, ដូងភុត, ឌូគា, ជូឡុងសាន, គឹមអុី, ណាជី, ណុងសុិន, សុិនឡុង, តាតកែ, តៃកនលីញ, បឹងថាញ់ហៃន, ត្រុងខាញ់ | ចិន និង វៀតណាម | ២៤ ៩៧៧ |

**ច្រករបៀងអាទិភាពទី ២ — ទន្លេមេគង្គ និង ដៃសំខាន់ៗ**

ជាផ្នែកខ្លះដោយលទ្ធផលនៃតំលៃជីវៈចម្រុះនៅមានកំរិតក្នុងចំណោមអ្នកធ្វើការសំរេចចិត្ត ប្រពន្ធ័អេកូស៊ីស្ទែមទន្លេរហូតមកដល់បច្ចុប្បន្នបានទទួលការវិនិយោគសំរាប់ការអភិរក្សតិចជាងប្រពន្ធ័អេកូស៊ីស្ទែមផ្សេងទៀតនៅតណ្ឌចិន និងការគាំទ្រក្នុងនាមជាប្រព័ន្ធតំបន់ការពាររបស់ជាតិ ។ ទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា រួមទាំងទន្លេស្រែពក ទន្លេសេសាន និង ទន្លេសេកុង បង្ហាញជាគំរូនៃប្រពន្ធ័អេកូស៊ីស្ទែមទន្លេដ៏ប្រសើរបំផុតដែលនៅសេសសល់ក្នុងតំបន់តណ្ឌចិន ។ តំលៃជីវៈចម្រុះនៃទន្លេទាំងនេះមិនទាន់ត្រូវបានវាយតំលៃឱ្យបានពេញលេញនៅឡើយទេ ជាពិសេសការប៉ាន់ប្រមាណការគំរាមកំហែងកំរិតពិភពលោកគ្រាន់តែត្រូវបានគេរៀបចំឡើងជាផ្នែកតូចៗអំពីប្រភេទសត្វ និងរុក្ខជាតិទឹកសាបដែលមានក្នុងតំបន់ទាំងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ច្រករបៀងត្រូវបានគេស្គាល់ថាជាកន្លែងសំខាន់សំរាប់ប្រភេទត្រីធំៗមួយចំនួន រួមទាំងត្រីត្រសក់ដែលជិតផុតពូជបំផុត (leaping barb) ត្រីថ្កុ ត្រីរាជ ត្រីបបែលប្រភេទ *Dasyatis laosensis* និងត្រីត្រសក់ប្រភេទ *Probarbus jullieni* ។ ច្រករបៀងនេះក៏មានពពួកសត្វអណ្តើកទឹកមួយចំនួនផងដែរ រួមមានកន្ធាយក្បាលកង្កែប(*Pelochelys cantorii)* ដែលជិតផុតពូជ ។ ជាងនេះទៀត ទន្លេមេគង្គ និងដៃសំខាន់ៗមានពពួកសត្វស្លាបដែលរស់នៅតាមដងទន្លេជាច្រើននៅសេសសល់ក្នុងតណ្ឌចិន ដែលរួមទាំងប្រភេទសត្វដែលរស់នៅប្រមូលផ្តុំសំខាន់ៗមួយចំនួនដូចជា ត្រដេវវិចទន្លេ (*Vanellus duvaucelii)* និងទន្រ្ទីតទន្លេ (*Glareola lacteal)* ។ អាស្រ័យដោយតំលៃទាំងនេះមួយផ្នែកនៃច្រករបៀងត្រូវបានចាត់បញ្ចូលជាតំបន់រ៉ាមសា ។ ការវិនិយោគរបស់ CEPF នៅតំបន់អាងទន្លេមេគង្គនឹងផ្តោតទៅលើទន្លេមេគង្គ និងដៃសំខាន់ៗដែលកំនត់ដោយការប្រជុំពិភាក្សារបស់អ្នកពាក់ពន្ធ័ ។ គំរោងដែលបានផ្តល់មូលនិធិក្រោមទិសដៅយុទ្ធសាស្រ្តទី៣អាចត្រូវបានអនុវត្តនៅកំឡុងពេល ឬក្រោយពីការកំណត់ច្រករបៀង ប៉ុន្តែត្រូវតែចូលរួមចំណែកទៅដល់ការអភិរក្សនៃពពួកសត្វ ឬទីតាំងអាទិភាពនៅក្នុងច្រករបៀង ដែលបានរៀបរាប់នៅក្នុងឯកសារប្រពន្ធ័អេកូស៊ីស្ទែម ។

## និរន្តរភាព

យុទ្ធសាស្រ្តវិនិយោគរបស់ CEPF សំរាប់តណ្ឌចិនត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវការអភិរក្សរយៈពេលយូរ និងផ្តល់ជាប្រយោជន៍ដល់ការកាត់បន្ថយភាពក្រីក្រនៅក្រោយពីការវិនិយោគរយៈពេល៥ឆ្នាំ ។ លក្ខណៈសំខាន់ៗនៃយុទ្ធសាស្រ្តវិនិយោគដែលរួមចំណែកទៅដល់ការធ្វើអោយមាននិរន្តរភាពរបស់ខ្លួននោះគឺ :

- មូលដ្ឋាននៃពតិមានអំពីស្ថានភាព និងរបាយនៃពពួករុក្ខជាតិ និងពពួកសត្វដែលរងការគំរាមកំហែងកំរិតពិភពលោកនឹងផ្តល់តាមរយៈអាទិភាពវិនិយោគ ១.៣ ១.៤ និង ១.៥ ដែលនឹងធានាថាការវិនិយោគលើការងារអភិរក្សទៅថ្ងៃអនាគតក្នុងតំបន់នឹងមានប្រសិទ្ធិភាពទាំងលើតំបន់ភូមិសាស្រ្ត និងការដោះស្រាយលើកត្តាគំរាមកំហែងផ្សេងៗ ។
- ចំណេះដឹងនៃអ្នកប្រើប្រាស់អំពីការប្រើប្រាស់ពពួកសត្វជាអាទិភាព និងផលិតផលចេញពីពួកវានឹងត្រូវបានបង្កើនតាមរយៈអាទិភាពវិនិយោគ ១.២ ស្របជាមួយគ្នានេះដែរពពួកសត្វដ៏សំខាន់ទាំងនេះនឹងត្រូវ

បានគេធ្វើអត្តសញ្ញាណកម្ម និងសង្គ្រោះតាមរយៈអាទិភាពវិនិយោគ ១.១ ដោយកាត់បន្ថយសំពាធលើពពួកសត្វព្រៃទាំងនេះក្រោយរយៈពេលនៃការវិនិយោគទៅទៀត ។

- ការគាំទ្ររបស់ប្រជាជននៅមូលដ្ឋានក្នុងការអភិរក្សជីវៈចម្រុះ នឹងត្រូវបានបង្កើតក្នុងតំបន់ជីវៈចម្រុះសំខាន់ៗទូទាំងតំបន់ តាមរយៈការរៀបចំនិងកសាងសមត្ថភាពអ្នកពាក់ពន្ធ័នៅមូលដ្ឋានក្រោមអាទិភាពវិនិយោគ ២.១ ។
- សមត្ថភាពមន្ត្រីប្រតិបត្តិក្នុងការពង្រឹងការគ្រប់គ្រងនឹងត្រូវបានពង្រឹងអោយកាន់តែខ្លាំងឡើងថែមទៀតតាមរយៈអាទិភាពវិនិយោគ ២.២ ដោយធានាថាការវិនិយោគទៅថ្ងៃអនាគតនៅក្នុងតំបន់ការពារធ្វើឡើងដោយរដ្ឋាភិបាល គឺមានប្រសិទ្ធិភាពជាងមុនក្នុងការត្រួតពិនិត្យមើលការធ្វើអាជីវកម្មហួសក៏រិត និងការគំរាមកំហែងចំបងៗដល់ជីវៈចម្រុះ ។
- ការពិនិត្យពិច័យអំពីជីវៈចម្រុះនឹងត្រូវធ្វើការបញ្ជ្រាបចូលទៅក្នុងផ្នែកផ្សេងៗទៀតតាមរយៈអាទិភាពវិនិយោគ ៣.១ និង ៣.២ ជាសំខាន់កាត់បន្ថយការគំរាមកំហែងនៅពេលអនាគតដល់ជីវៈចម្រុះ ជាពិសេសនៅច្រករបៀងអាទិភាព ។
- សមត្ថភាពនៃអង្គការសង្គមស៊ីវិលដែលផ្តោតលើការអភិរក្សពូជ ការអភិរក្សដោយផ្អែកលើសហគមន៏ ការវិភាគគោលនយោបាយ ការរៀបចំសហគមន៏ និងការលើកកំពស់ការយល់ដឹងនឹងត្រូវបានពង្រឹងតាមរយៈទិសដៅជាយុទ្ធសាស្ត្រ ១ ២ ៣ និង ៤ ដើម្បីធានាថាការវិនិយោគនៅថ្ងៃអនាគតលើការងារអភិរក្សតាមរយៈអង្គការសង្គមស៊ីវិលនឹងមានប្រសិទ្ធិភាពខ្ពស់ជាងមុន ។
- ក្រុមអនុវត្តប្រចាំតំបន់ដែលបានបង្កើតឡើងក្រោមទិសដៅយុទ្ធសាស្ត្រទី ៤ នឹងបង្កើតទំនាក់ទំនងការងារដ៏សំខាន់នៅក្នុងកម្មវិធីរបស់ខ្លួន និងជាមួយដៃគូផ្តល់ជំនួយរបស់CEPF និងភ្នាក់ងារអនុវត្តផ្សេងៗទៀតនៅទូទាំងតំបន់ជីវៈចម្រុះហតស្ពត ក៏ដូចជាជាមួយនិងរដ្ឋាភិបាល និងស្ថាប័នដទៃទៀតដែលនឹងជួយគាំទ្រ និងឱ្យការងារសំរេចទៅបានក្នុងកំឡុងពេលវិនិយោគនេះ ។

## តារាង ២ ពពួកសត្វជាអាទិភាពសំរាប់ការវិនិយោគ CEPF នៅឥណ្ឌូចិន

| ពពួកសត្វជាអាទិភាព | តំរូវការអភិរក្សដែលទាមទារសកម្មភាពផ្តោតលើពពួកសត្វ | តំរូវការធ្វើបច្ចុប្បន្នភាពព័ត៌មាន |
|---|---|---|
| ថនិកសត្វ (២៦ប្រភេទ) | | |
| គោព្រៃ (Kouprey) *Bos sauveli* | | ត្រូវការ |
| ក្របីព្រៃ (Wild Water Buffalo) *Bubalus bubalis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ខ្លាលឿងមាស (Asian Golden Cat) *Catopuma temminckii* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| រមាំង (Eld's Deer) *Cervus eldii* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ<br>ការគ្រប់គ្រងចំនួនដែលមាន | |
| សំពោចភេ (Otter Civet) *Cynogale bennettii* | | ត្រូវការ |
| រមាសសក់ក្រហម (Hairy Rhinoceros) *Dicerorhinus sumatrensis* | ត្រួតពិនិត្យលើការកេងប្រវ័ញ្ចហួសហេតុ | |
| ដំរី (Asian Elephant) *Elephas maximus* | ការបន្ធូរបន្ថយជំលោះមនុស្សនិងដំរី<br>ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| កំពឹងដូងធ្មេញតូច (Small-toothed Mole) *Euroscaptor parvidens* | | ត្រូវការ |
| ភេខ្លួនរលោង (Smooth-coated Otter) *Lutrogale perspicillata* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ខ្លាពពក (Clouded Leopard) *Neofelis nebulosa* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ទោច (Black Crested Gibbon) *Nomascus concolor* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ប្រចៀវម៉្យាង (Wroughton's Free-tailed Bat) *Otomops wroughtoni* | | ត្រូវការ |
| ខ្លាធំ (Tiger) *Panthera tigris* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ប្រចៀវច្រមុះសំប៉ែតវៀតណាម (Vietnam Leaf-nosed Bat) *Paracoelops megalotis* | | ត្រូវការ |
| ខ្លាភ្នំថ្មកែវ (Marbled Cat) *Pardofelis marmorata* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ខ្លាត្រី (Fishing Cat) *Prionailurus viverrinus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| សត្វសៅឡា (Saola) *Pseudoryx nghetinhensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ស្វាក្រវ៉ាត់ឬស្វាកន្ទុយស(Red-shanked Douc) *Pygathrix nemaeus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ស្វាម្យ៉ាង (Black-shanked Douc) *Pygathrix nigripes* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| រមាសកុយមួយ (Lesser One-horned Rhinoceros) *Rhinoceros sondaicus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ<br>ការគ្រប់គ្រងលើចំនួនដែលសកម្ម | |
| ស្វាច្រមុះខ្លី(Tonkin Snub-nosed Monkey) *Rhinopithecus avunculus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ស្វាម្យ៉ាង (Delacour's leaf Monkey) *Trachypithecus delacouri* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ស្វាម្យ៉ាង (Francois's Leaf Monkey) *Trachypithecus francoisi* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |

| ពពួកសត្វជាអាទិភាព | តម្រូវការអភិរក្សដែលទាមទារសកម្មភាពផ្តោតលើពពួកសត្វ | តម្រូវការធ្វើបច្ចុប្បន្នភាពព័ត៌មាន |
|---|---|---|
| ស្វាក្បាលស (White-headed Leaf Monkey) *Trachypithecus poliocephalus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| (Chapa Pygmy Doormouse) *Typhlomys chapaensis* | | ត្រូវការ |
| ខ្លាឃ្មុំធំ (Asian Black Bear) *Ursus thibetanus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| | | |
| ***សត្វស្លាប*** *(១២ប្រភេទ)* | | |
| ទាព្រៃស្លាបស (White-winged Duck) *Cairina scutulata* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រចៀកកាំទន្លេភ្នែកស (White-eyed River-martin) *Eurychelidon sirintarae* | | ត្រូវការ |
| ខ្វែក (White-eared Night-heron) *Gorsachius magnificus* | | ត្រូវការ |
| ក្រៀល (Sarus Crane) *Grus antigone* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្មាតផេះ (White-rumped Vulture) *Gyps bengalensis* | ការផ្តល់អាហារឱ្យបានគ្រប់គ្រាន់<br>ត្រួតពិនិត្យលើការរំខាន | |
| ត្មាតត្នោត (Slender-billed Vulture) *Gyps tenuirostris* | ការផ្តល់អាហារឱ្យបានគ្រប់គ្រាន់<br>ត្រួតពិនិត្យលើការរំខាន | |
| ពពូលទឹក (Masked Finfoot) *Heliopais personata* | ត្រួតពិនិត្យលើការរំខាននៅតាមផ្លូវទឹក | |
| ត្រដក់ធំ (Greater Adjutant) *Leptoptilos dubius* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រដក់តូច (Lesser Adjutant) *Leptoptilos javanicus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ក្ងោក (Green Peafowl) *Pavo muticus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រយ៉ងចំកំកស (White-shouldered Ibis) *Pseudibis davisoni* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រយ៉ងយក្ស (Giant Ibis) *Thaumatibis gigantea* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| | | |
| ***ឧរង្គសត្វ*** *(២១ប្រភេទ)* | | |
| កន្ធាយអាស៊ី (Asiatic Softshell Turtle) *Amyda cartilaginea* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកពត៌ (Painted Terrapin) *Callagur borneoensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកកក្រហម (Red-necked Pond Turtle) *Chinemys nigricans* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | ត្រូវការ |
| អណ្តើកទ្រនុងបី (Chinese Three-keeled Pond Turtle) *Chinemys reevesii* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| កន្ធាយឆ្នូត(Striped Narrow-headed Softshell Turtle) *Chitra chitra* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ក្រពើត្រី (Siamese Crocodile) *Crocodylus siamensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកបិទមុខឥណ្ឌូចិន(Indochinese Box Turtle) *Cuora galbinifrons* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |

| ពពួកសត្វជាអាទិភាព | តំរូវការអភិរក្សដែលទាមទារសកម្មភាពផ្តោតលើពពួកសត្វ | តំរូវការធ្វើបច្ចុប្បន្នភាពព័ត៌មាន |
|---|---|---|
| អណ្តើកក្អែកឆ្នូតបី (Chinese Three-striped Box Turtle) *Cuora trifasciata* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកបិទមុខហ្សូ (Zhou's Box Turtle) *Cuora zhoui* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | ត្រូវការ |
| អណ្តើកសោមទ្រនុងបី (Black-breasted Leaf Turtle) *Geoemyda spengleri* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកក្របីក្បាលលឿង (Yellow-headed Temple Turtle) *Hieremys annandalii* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកសោមបន្លាភ្លៅ (Asian Giant Tortoise) *Manouria emys* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកតិចកាលបន្លាមួយ(Impressed Tortoise) *Manouria impressa* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកអាណាម(Vietnamese Pond Turtle) *Mauremys annamensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | ត្រូវការ |
| អណ្តើកតឹកកាល់កលឿង(Asian Yellow Pond Turtle) *Mauremys mutica* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកឆ្នូតក (Chinese Strip-necked Turtle) *Ocadia sinensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| កន្ធាយពកក (Wattle-necked Softshell Turtle) *Palea steindachneri* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| កន្ធាយក្បាលកង្កែប(Asian Giant Softshell Turtle) *Pelochelys cantorii* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| កន្ធាយក្បាលកង្កែបអាស៊ីខាងកើត(East Asian Giant Softshell Turtle) *Rafetus swinhoei* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | ត្រូវការ |
| អណ្តើកម្យ៉ាង (Bealed's eyed Turtle) *Sacalia bealei* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| អណ្តើកភ្នែកបួន (Four-eyed Turtle) *Sacalia quadriocellata* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| | | |
| *ត្រី (៨ប្រភេទ)* | | |
| ត្រីបបែលប្រភេទ (Mekong Freshwater Stingray) *Dasyatis laosensis* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីបបែលប្រភេទ (Giant Freshwater Stingray) *Himantura chaophraya* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីបបែលប្រភេទ (Marbled Freshwater Stingray) *Himantura oxyrhynchus* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីបបែលប្រភេទ (White-edged Freshwater Whipray) *Himantura signifer* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីរាជ (Giant Catfish) *Pangasianodon gigas* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីថ្កី (Freshwater Sawfish) *Pristis microdon* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីត្រសក (Jullien's Golden Carp) *Probarbus jullieni* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |
| ត្រីក្បក (Laotian Shad) *Tenualosa thibaudeaui* | ត្រួតពិនិត្យលើការធ្វើអាជីវកម្មហួសហេតុ | |

**កំណត់សំគាល់:** * = បន្ថែមពីលើពពួកសត្វដែលបានរាយនៅក្នុងតារាង ប្រភេទរុក្ខជាតិដែលរងការគំរាមកំហែងក៏រិតពិភពលោកទាំង ២៤៨ប្រភេទនៅតណ្ឌចិន ក៏ត្រូវបានចាត់ទុកជាអាទិភាពសំរាប់ការវិនិយោគរបស់ CEPF ផងដែរ ។

# លក្ខណៈវិនិច្ឆ័យសមស្រប

## អ្នកណាខ្លះអាចដាក់សំណើសុំថវិកាពីមូលនិធិ CEPF?

អង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ សហគ្រាសឯកជន និង ស្ថាប័នសង្គមស៊ីវិលផ្សេងៗទៀតអាចដាក់សំណើសុំថវិការនេះបាន ។ ស្ថាប័នទាំងនេះត្រូវតែមានគណនីផ្ទាល់ខ្លួនក្នុងធនាគារ និងពិសេសត្រូវបានចុះបញ្ជីក្រោមច្បាប់របស់ប្រទេសដែលពាក់ព័ន្ធ ដើម្បីអាចទទួលអំណោយមនុស្សធម៌នេះបាន ។ សហគ្រាស ឬវិទ្យាស្ថានរបស់រដ្ឋាភិបាលក៏មានសិទ្ធិដាក់សំណើសុំថវិកានេះបានដែរប្រសិនបើពួកគេអាចបង្ហាញថា ទី១. មានភាពឯករាជ្យតាមផ្លូវច្បាប់ក្នុងការដឹកនាំស្ថាប័ននោះ ទី២. មានសិទ្ធិអំណាចក្នុងការដាក់សំណើសុំជំនួយ និងទទួលជំនួយពីមូលនិធិឯកជន និងទី៣. មិនមានអភ័យឯកសិទ្ធពិសេសណាមួយឡើយ ។

ទោះបីជាលក្ខណៈវិនិច្ឆ័យសំរាប់អ្នកដាក់សំណើត្រូវបានរៀបរាប់យ៉ាងទូលាយដូចខាងលើក៏ដោយ ក៏ការចង់បានសំខាន់មួយគឺត្រូវបានប្រគល់អោយស្ថាប័នទាំងឡាយណាដែលអាចបង្ហាញយ៉ាងច្បាស់ថាខ្លួនជា ស្ថាប័នសង្គមស៊ីវិល និងអាចកសាងសមត្ថភាពសង្គមស៊ីវិលបាន ត្រូវបានលើកទឹកចិត្តជាពិសេសក្នុងការដាក់សំណើ ។ រាល់ពាក្យសុំទាំងឡាយដែលរួមបញ្ចូលអង្គការសង្គមស៊ីវិលដែលសមត្ថភាពនៅមានកំរិត (ពោលគឺស្ថាប័នទាំងនេះមិនអាចដាក់សំណើថវិកាបានដោយមិនអាចឆ្លើយតបនិងលក្ខណៈវិនិច្ឆ័យ ឬ ក៏គ្មានសមត្ថភាពក្នុងរៀបចំសំណើ ឧទាហរណ៍ដូចជាក្រុមសហគមន៍ជាដើម) ក៏ត្រូវបានលើកទឹកចិត្តផងដែរ ។ ម្យ៉ាងទៀត ឯកត្តៈជន (បុគ្គលម្នាក់) ត្រូវបានលើកទឹកចិត្តឱ្យធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងការរៀបចំដាក់សំណើជាជាងដាក់សំណើសុំថវិកាដោយផ្ទាល់ក្នុងនាមជាបុគ្គល ។ អ្វីមួយដែលលោក-លោកស្រីមានមន្ទិលសង្ស័យ ឬមិនច្បាស់អំពីលក្ខណៈវិនិច្ឆ័យក្នុងការដាក់សំណើសុំថវិកា ឬក៏ភាពអាចទទួលថវិកាបានពីមូលនិធិCEPF សូមធ្វើការទំនាក់ទំនងមកក្រុមការងារប្រចាំតំបន់របស់អង្គការជីវិតសត្វស្លាបអន្តរជាតិតាមរយៈអ៊ីម៉ែល: cepf-rit@birdlife.org.vn ។

## តើសំណើសុំថវិកាប្រភេទណាដែល CEPF ផ្តល់ការអនុម័តយល់ព្រម?

គំរោងនិមួយៗត្រូវតែគាំទ្រដល់ទិសដៅយុទ្ធសាស្ត្រមួយក្នុងចំណោមទិសដៅយុទ្ធសាស្ត្រទាំងបីខាងដើម (ពីព្រោះទិសដៅយុទ្ធសាស្ត្រទីបួនអង្គការជីវិតសត្វស្លាបអន្តរជាតិបាននិងកំពុងអនុវត្ត) មានចែងក្នុងយុទ្ធសាស្ត្រវិនិយោគរបស់CEPFសំរាប់តំបន់ឥណ្ឌូ-ភូមា ទើបអាចមានសិទ្ធិទទួលបានមូលនិធិនេះ ។ យុទ្ធសាស្ត្រវិនិយោគនិងទិសដៅយុទ្ធសាស្ត្រសំរាប់តំបន់ឥណ្ឌូចិនត្រូវបានរៀបរាប់ដោយសង្ខេបនៅក្នុងផ្នែកដើមដំបូងនៃឯកសារនេះ ហើយសំរាប់ឯកសារលំអិតសូមចូលទៅក្នុងគេហទំព័រ:
http://cepf.net/Documents/final.indoburma_indochina.ep.pdf (PDF 2.5MB)

គំរោងសំណើថវិកា **ត្រូវតែ** ឆ្លើយតបនិងលក្ខណៈវិនិច្ឆ័យ**ទាំងអស់**ដូចខាងក្រោម ៖

- គំរោងត្រូវអនុវត្តនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម ឬភាគខ្លះនៃប្រទេសចិនដែលស្ថិតក្នុងតំបន់ហតស្ពតឥណ្ឌូ-ភូមា (រូបភាពទី១)
- គំរោងត្រូវស្ថិតក្នុងប្រទេសណាដែលទទួលបានការអនុម័តយល់ព្រមលើស្ថាប័នបង្គោលរបស់មូលនិធិបរិស្ថានពិភពលោក (GEF Focal Point) (គិតត្រឹមខែមិថុនា ឆ្នាំ២០០៩ មានតែប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមទេដែលផ្តល់ការគាំទ្រនេះ) ដូច្នេះការប្រកាសទទួលសំណើសង្ខេបលើកនេះមិនរាប់បញ្ចូលប្រទេសទាំងប្រាំដូចបានរៀបរាប់ខាងលើនោះទេ ។
- ថវិកាដែលផ្តល់អោយនឹងមិនត្រូវប្រើសំរាប់ទិញដី រើទីលំនៅរបស់ប្រជាជនដោយគ្មានការស្ម័គ្រចិត្ត (រួមបញ្ចូលទាំងការកែប្រែការប្រើប្រាស់ដីផងដែរ) ឬសកម្មភាពទាំងឡាយណាដែលប៉ះពាល់ជាអវិជ្ជមានដល់ធនធានវប្បធម៌ធម្មជាតិ រួមមានធនធានទាំងឡាយណាដែលមានសារៈសំខាន់ដល់ប្រជាជនក្នុងសហគមន៍ ។
- ថវិកាដែលផ្តល់ឱ្យនឹងមិនត្រូវប្រើសំរាប់សកម្មភាពទាំងឡាយដែលធ្វើអោយប៉ះដល់ផលប្រយោជន៍ជនជាតិភាគតិច ឬអនុវត្តសកម្មភាពនៅទីកន្លែងដែលជនជាតិភាគតិចមិនផ្តល់ការគាំទ្រឱ្យបានទូលំទូលាយ ។
- ថវិកាដែលផ្តល់អោយនឹងមិនត្រូវបានប្រើសំរាប់រុះរើ ឬធ្វើអោយខូចដល់ទ្រព្យសម្បត្តិផ្នែកវប្បធម៌ ដែលមានដូចជាទីតាំងដែលមានតំលៃផ្នែកបុរាណវត្ថុវិទ្យា ផ្នែកបាសាណិភូតវិទ្យា ផ្នែកប្រវិត្តិសាស្ត្រ សាសនា ឬក៏តំលៃដែលមានតែមួយក្នុងលោករបស់ធម្មជាតិ)
- រាល់សកម្មភាពដែលស្នើឡើងត្រូវអនុលោមតាមគោលនយោបាយការពារ និងសង្គមរបស់ធនាគារពិភពលោក: http://go.worldbank.org/WTA1ODE7T0;
- សំណើគំរោងទាំងឡាយគោរពតាមគោលការណ៍ណែនាំ ឬភូមិសាស្ត្រ ឬប្រធានបទបន្ថែមដែលបានកំណត់នៅពេលផ្សព្វផ្សាយការទទួលយកសំណើសង្ខេបរបស់គំរោង ។ ការប្រកាសទទួលយកសំណើសង្ខេបនេះនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងនៅក្នុងគេហទំព័រដូចខាងក្រោមនេះ: http://www.birdlifeindochina.org/cepf

# ដំណើរការដាក់សំណើ

ការប្រកាសទទួលសំណើសង្ខេបរបស់គំរោងនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ រួមទាំងតាមរយៈគេហទំព័រ: http://www.birdlifeindochina.org/cepf ផងដែរ ។ ការប្រកាសទទួលសំណើសង្ខេបលើកដំបូងនឹងត្រូវផ្សព្វផ្សាយនៅមុនដំណាច់ខែកញ្ញា ឆ្នាំ២០០៨ និងកាលបរិច្ឆេទឈប់ទទួលពាក្យមិនលើសពីដំណាច់ខែធ្នូ ឆ្នាំ២០០៨ ឡើយ ។ ក្នុងការប្រកាសនេះនឹងរៀបរាប់ផងដែរពីគោលការណ៍ណែនាំនៃវិសាលភាពភូមិសាស្ត្រ និងនិតិវិធីក្នុងការដាក់សំណើ ។ ទោះបីយ៉ាងណាដ៏ដោយ និយាយឱ្យខ្លី ដើម្បីដាក់សំណើសុំថវិកាពីមូលនិធិ CEPF អ្នកដាក់សំណើទាំងអស់ត្រូវដាក់សំណើសង្ខេបរបស់គំរោងជាមុនសិន ។ គំរូនៃសំណើសង្ខេបនេះអាចយកបានពីគេហទំព័រ: http://www.cepf.net/Documents/cepf.loi.doc ។ ប៉ុន្តែមុនពេលដាក់សំណើសង្ខេបរបស់គំរោងជាផ្លូវការអ្នកដាក់ពាក្យទាំងអស់ត្រូវបានជំរុញឱ្យធ្វើការពិភាក្សាជាមុនអំពីគោលគំនិតរបស់គំរោងដែលនឹងស្នើ ក៏ដូចជាអំពីលក្ខណៈវិនិច្ឆ័យដែលអាចដាក់សំណើបាន ជាមួយក្រុមអនុវត្តន៏ការងារប្រចាំតំបន់របស់អង្គការជីវិតសត្វស្លាបតាមរយៈអ៊ីម៉ែល: cepf-rit@birdlife.org.vn ។

សំរាប់គំរោងដែលស្នើសុំថវិកាលើសពី ២០.០០០ ដុល្លារ នៅពេលដែលសំណើសង្ខេបត្រូវបានរៀបចំរួចរាល់ហើយនោះ សូមផ្ញើរអ៊ីម៉ែលទៅ : cepfgrants@conservation.org ដោយត្រូវភ្ជាប់មកជាមួយនិងពាក្យស្នើសុំលំអិតផងដែរ ។ លោក-លោកស្រីនឹងទទួលបានការជូនដំណឹងពីការទទួលបានសំណើ ហើយសំណើនេះនឹងត្រូវបញ្ជូនទៅក្រុមការងារដែលទទួលខុសត្រូវលើរឿងនេះ ។ លោក-លោកស្រីនឹងត្រូវគេទំនាក់ទំនងប្រាប់ពីជំហានដែលត្រូវធ្វើបន្តបន្ទាប់ទៀត ។ រាល់សំណួរ និងចំងល់ផ្សេងៗពាក់ព័ន្ធនិងដំណើរការនេះ លោក-លោកស្រីអាចសាកសួរបានតាមរយៈអ៊ីម៉ែល: cepfgrants@conservation.org ។

សំរាប់សំណើដែលត្រូវការថវិកា ២០.០០០ដុល្លា ឬ តិចជាងនេះ សំណើសង្ខេបរបស់គំរោងមានភ្ជាប់ជាមួយនិងសំណើគំរោងលំអិត ។ ប្រសិនបើសំណើសង្ខេបដែលដាក់សំណើសុំថវិកាច្រើនជាង២០.០០០ដុល្លារទទួលបានការយល់ព្រមពីក្រុមការងារទទួលសំណើ នោះអ្នកដាក់សំណើនឹងត្រូវបានគេជូនដំណឹង និងអញ្ជើញអោយមកដាក់គំរោងសំណើលំអិតបន្តទៀត ។

នៅពេលដែលសំណើសង្ខេបសុំជំនួយខ្នាតតូចត្រូវបានរៀបចំរួចរាល់ហើយ សូមលោក-លោកស្រីផ្ញើអ៊ីម៉ែលទៅកាន់ : cepf-rit@birdlife.org.vn ដោយភ្ជាប់ជាមួយនឹងពាក្យសុំលំអិត ។ លោក-លោកស្រីនឹងទទួលបានការជូនដំណឹងពីការទទួលបានសំណើ ហើយសំណើនេះនឹងត្រូវបញ្ជូនទៅក្រុមការងារដែលទទួលខុសត្រូវលើរឿងនេះ ។ លោក-លោកស្រីនឹងត្រូវគេទំនាក់ទំនងប្រាប់ពីជំហានដែលត្រូវធ្វើបន្តបន្ទាប់ទៀត ។ រាល់សំណួរ និងចំងល់ផ្សេងៗពាក់ព័ន្ធនិងដំណើរការនេះលោក-លោកស្រីអាចសាកសួរតាមរយៈអ៊ីម៉ែលដូចខាងក្រោម: cepf-rit@birdlife.org.vn ។

សំរាប់ព័ត៌មានបន្ថែមទៀត សូមចូលទៅក្នុងគេហទំព័រដែលមានអាសយដ្ឋានដូចខាងក្រោម:
http://www.birdlifeindochina.org/cepf or http://cepf.net/grants/apply/Pages/default.aspx